# វត្ថុផ្សព្វផ្សាយ

## ស្តីពី

# គោលការណ៍គ្រឹះរបស់ចលនា ច្បាប់មនុស្សធម៌អន្តរជាតិ

# ការលើកកម្ពស់តម្លៃមនុស្សធម៌

ឯកសារ១ព្រឹក រៀបចំដោយ នាយកដ្ឋានទំនាក់ទំនង កាកបាទក្រហមកម្ពុជា
ធ្វើបច្ចុប្បន្នកម្ម ឆ្នាំ ២០២០

# មាតិកា

១. ប្រវត្តិរបស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

២. សមាសភាគរបស់ចលនា

៣. លក្ខណៈវិនិច្ឆ័យ១០យ៉ាង នៃការទទួលស្គាល់សមាគមជាតិ

៤. គោលការណ៍គ្រឹះទាំង ៧ ប្រការ

៥. បដិរូប កាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

៦. មូលដ្ឋានច្បាប់មនុស្សធម៌អន្តរជាតិ

៧. កាកបាទក្រហមកម្ពុជា

៨. សកម្មភាព សាខាកាកបាទក្រហមកម្ពុជា

# ១-ប្រវត្តិចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម






- សមរភូមិសុលហ្វេរីណូ (ភាគខាងជើងប្រទេស អ៊ីតាលី) កងទ័ពបារាំង និង អ៊ីតាលី រួមគ្នាវាយប្រយុទ្ធនឹងកងទ័ពអូទ្រីស នៅថ្ងៃទី២៤ មិថុនា ១៨៥៩។ រយៈពេលជាង ១៦ ម៉ោង បានបណ្តាលឲ្យមានអ្នកស្លាប់ និងអ្នករបួសចំនួនជាង ៤ ម៉ឺន នាក់។
- លោក ហង់រី ឌុយណង់ ពាណិជ្ជករជាតិស្វីសបានផ្តើមគំនិតប្រមូលអ្នកស្ម័គ្រចិត្តជួយសង្គ្រោះ អ្នករបួសទាំងនោះ ដោយពុំមានគិតថាខាងណាជាមិត្ត ខាងណាជាសត្រូវឡើយ។

# ១-ប្រវត្តិចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម




**ក្នុងឆ្នាំ ១៨៦២ លោក ហង់រី ឌុយណង់ ផ្សព្វផ្សាយសៀវភៅ "អនុស្សាវរីយ៍នៅ សុលហ្វេរីណូ" ដែលក្នុងនោះបានផ្តល់នូវគោលគំនិត ២ គឺ៖**

១- បង្កើតគណៈកម្មាធិការជួយសង្គ្រោះអ្នករបួស ហើយក្នុងពេលមានសន្តិភាពត្រូវបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត ឲ្យចេះជួយព្យាបាលអ្នករបួសពេលមានសង្គ្រាម។

២- បង្កើតកិច្ចព្រមព្រៀងអន្តរជាតិសម្រាប់ទទួលស្គាល់ និងការពារគណៈកម្មាធិការជួយសង្គ្រោះអ្នករបួស។

## ១.១ ស្ថាបនិករបស់ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម



លោក ហង់រី ឌុយណង់



ឧត្តមសេនីយ ហង់រី ឌុយហ្វួរ



ឧត្តមសេនីយ ម៉យនៀ



វេជ្ជបណ្ឌិត ល្វីស អាភា



វេជ្ជបណ្ឌិត ជី ម៉ូណ័រ

“សមាគមអន្តរជាតិសង្គ្រោះអ្នករបួស” បានបង្កើតឡើងនៅថ្ងៃទី ១៧ កុម្ភៈ ១៨៦៣។
នៅឆ្នាំ ១៨៦៧ សមាគមនោះ ក៏បានប្រែឈ្មោះទៅជា “គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម”។

# ប្រវត្តិចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម

## ១.២ បដិរូបកាកបាទក្រហម ត្រូវបានកំណត់ប្រើជាអត្តសញ្ញាណ

**នៅឆ្នាំ ១៨៦៣ មានព្រឹត្តិការណ៍សំខាន់ ២ គឺ៖**

១- ការកំណត់ បដិរូបកាកបាទក្រហម ជាអត្តសញ្ញាណ
ការពារ និងសម្គាល់សេវាកម្មសង្គ្រោះអ្នករបួស។

២- ការបង្កើតឲ្យមានសមាគមជាតិ នៅតាមប្រទេសនានា
ធ្វើសកម្មភាពផ្ដល់ជំនួយ។

ប្រការដ៏សំខាន់ទាំង២ខាងលើនេះ ត្រូវបានចងក្រងជាឯកសារ មូលដ្ឋានច្បាប់នៃអនុសញ្ញាហ្សឺណែវទី១
ដែលត្រូវបានចុះហត្ថលេខាជាអន្តរជាតិ នៅឆ្នាំ១៨៦៤។

# ២-សមាសភាគរបស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

សមាសភាគរបស់ ចលនា មាន៣ គឺ៖

១- គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម ដែលហៅកាត់ជាភាសាអង់គ្លេសថា អាយ.ស៊ី.អរ.ស៊ី (ICRC) ឬ ជាភាសាបារាំងថា សេ.អ៊ី.សេអ៊ែរ (CICR) ។

២- សហព័ន្ធអន្តរជាតិ នៃសមាគមកាកបាទក្រហម អឌ្ឍចន្ទក្រហម

៣- សមាគមជាតិ នៃប្រទេសនីមួយៗ ( កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម )

ដែលរួមគ្នាបង្កើតបានជា ចលនាកាកបាទក្រហម ហើយនៅឆ្នាំ១៩៨៦
បានទទួលឈ្មោះជាផ្លូវការថា
"ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម" ឬ ហៅកាត់ថា "ចលនា"។

## គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម

## សមាសភាគរបស់ ចលនា ៖

- គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម ដែលហៅកាត់ជាភាសាអង់គ្លេសថា អាយ.ស៊ី.អរ.ស៊ី (ICRC) ឬ ជាភាសាបារាំងថា សេ.អ៊ី.សេ.អ៊ែរ (CICR)។ អាយ.ស៊ី.អរ.ស៊ី បានបង្កើតឡើង នៅឆ្នាំ ១៨៦៣ ដោយប្រទេសស្វីស គឺជាអង្គការមិនលំអៀង អព្យាក្រឹត ឯករាជ្យ។ អាយ.ស៊ី.អរ.ស៊ី មានបេសកកម្មមនុស្សធម៌ដ៏ថ្លៃថ្លាបំផុត គឺគាំពារអាយុជីវិត និងសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះដោយសារសង្គ្រាម ដោយអំពើហិង្សាផ្ទៃក្នុង ហើយ និងផ្ដល់ការឧបត្ថម្ភដល់ជនរងគ្រោះទាំងនោះ។

ICRC

**អាយ.ស៊ី.អរ.ស៊ី**

**បង្កើតឡើងថ្ងៃទី ១៧ កុម្ភៈ ១៨៦៣**

សមាសភាគរបស់ចលនាអន្តរជាតិ កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

## សហព័ន្ធអន្តរជាតិ នៃសមាគម
## កាកបាទក្រហម និងអឌ្ឍចន្ទក្រហម

International Federation of the
Red Cross Red Crescent Societies

ហៅកាត់ថា សហពន្ធ័អន្តរជាតិ បានបង្កើតឡើងនៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ១៩១៩។ សហព័ន្ធអន្តរជាតិបំពេញការងារលើមូលដ្ឋានគោលការណ៍គ្រឹះរបស់ ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម ក្នុងការជួយជំរុញជួយសម្រួល និងលើកកម្ពស់ឲ្យមាន សកម្មភាពមនុស្សធម៌កើតមាននៅក្នុងប្រទេសរបស់សមាគមជាតិទាំងឡាយ ដែលជាសមាជិក ដើម្បីធ្វើយ៉ាងណាកែលម្អស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋងាយរងគ្រោះបំផុត។ សហព័ន្ធអន្តរជាតិ ជាអ្នកចង្អុលទិស និងជាអ្នកសម្របសម្រួលដល់ការងារផ្តល់ជំនួយអន្តរជាតិ ជួយដល់ជនរងគ្រោះដោយមហន្តរាយគ្រប់ប្រភេទ ជួយដល់ជនភៀសខ្លួន និងគ្រោះបន្ទាន់ ផ្នែកសុខភាព។

# សមាសភាគរបស់ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម

សមាគមជាតិ
កាកបាទក្រហម អឌ្ឍចន្ទក្រហម
លើពិភពលោក
ឆ្នាំ ២០១៩ មានចំនួន ១៩១



សមាគមជាតិនៃប្រទេសនីមួយៗ ធ្វើសកម្មភាពជាអ្នកជំនួយការផ្នែកសកម្មភាពមនុស្សធម៌ ឲ្យអាជ្ញាធរសាធារណៈ ក្នុងប្រទេសរបស់ខ្លួន និងផ្តល់វិសាលភាពនៃសេវាកម្ម ផ្នែកជំនួយសង្គ្រោះ គ្រោះមហន្តរាយ ជំនួយសង្គ្រោះផ្នែកអប់រំ សុខភាព និងជួយអភិវឌ្ឍសង្គម។ សមាគមជាតិ ធ្វើសកម្មភាព ទាំងក្នុងពេលមានសន្តិភាព និងក្នុងពេលមានសង្គ្រាម ត្រូវទ្រទ្រង់សេវាកម្មពេទ្យយោធា។

# កាកបាទក្រហមកម្ពុជា

**បង្កើតឡើង**

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៥៥

បានការទទួលស្គាល់ពី អាយ.ស៊ី.អរ.ស៊ី នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៦០ និង

បានបញ្ចូលជាសមាជិក សហព័ន្ធអន្តរជាតិ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៦០។

បានទទួលស្គាល់ដោយ ព្រះរាជក្រឹត្យលេខ៣៧៨/នស ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥៨

និងបានទទួលស្គាល់ឡើងវិញ

ដោយព្រះរាជក្រឹត្យ នស/រកត/០៥០២/១១៣

ថ្ងៃទី៦ ឧសភា ២០០២។

**កាកបាទក្រហមកម្ពុជា ជាសមាជិកទី ៨៥ របស់សហព័ន្ធអន្តរជាតិ**

## លក្ខណៈវិនិច្ឆ័យ ១០ យ៉ាង នៃការទទួលស្គាល់សមាគមជាតិ

១. ជាសមាគមជាតិ ដែលបានបង្កើតឡើងក្នុងបូរណភាពដែនដី នៃរដ្ឋឯករាជ្យមួយ ដែលអនុសញ្ញាហ្សឺណែវមានសុពលភាព ។

២. ជាសមាគមជាតិតែមួយគត់ របស់រដ្ឋឯករាជ្យមួយ ហើយមានគណៈអភិបាលមួយជាអ្នកចង្អុលទិស ។

៣. មានការទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាលស្របច្បាប់របស់ប្រទេស ដោយឈរលើមូលដ្ឋាននៃអនុសញ្ញាហ្សឺណែវ ។

៤. មានស្វ័យភាព ដែលអាចឲ្យសមាគមជាតិធ្វើប្រតិបត្តិការបានយ៉ាងងាយស្រួល តាមគោលការណ៍គ្រឹះទាំង ៧ របស់ចលនា (ភាពមនុស្សធម៌ ភាពមិនលំអៀង អព្យាក្រឹតភាព ឯករាជ្យភាព សេវាកម្មស្ម័គ្រចិត្ត ឯកភាព សកលភាព) ។

៥. ឈ្មោះបដិរូប ទោះបីជាប្រើ កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហមក៏ដោយ ត្រូវតែអនុលោមទៅតាមអនុសញ្ញា ហ្សឺណែវ ។

# លក្ខណៈវិនិច្ឆ័យ ១០ យ៉ាង នៃការទទួលស្គាល់សមាគមជាតិ ( ត )

៦. មានសមត្ថភាពបំពេញកាតព្វកិច្ចនានា តាមលក្ខន្តិកៈរបស់ខ្លួន ហើយនៅក្នុងពេលមានសន្តិភាព ត្រូវមានលក្ខណៈត្រៀមបំពេញកាតព្វកិច្ចតាមនីតិក្រម នៅពេលណាមានទំនាស់ប្រដាប់អាវុធកើតឡើង ។

៧. មានសកម្មភាពទូទាំងផ្ទៃប្រទេស ។

៨. ត្រូវពង្រីកសមាជិកភាព ជ្រើសរើសអ្នកស្ម័គ្រចិត្ត និង មន្រ្តី-បុគ្គលិកធ្វើការ ដោយមិនត្រូវ ប្រកាន់ពូជសាសន៍ ភេទ វណ្ណៈ សាសនា ឬ ទស្សននយោបាយឡើយ ។

៩. ត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវលក្ខន្តិកៈរបស់ចលនា រួមសហការជាមួយគ្នា រួបរួមគ្នានៅក្នុងចំណោមសមាសភាគទាំងអស់របស់ចលនា ហើយត្រូវតែសហការគ្នាឲ្យបានល្អជានិច្ច ។

១០. ត្រូវគោរពគោលការណ៍គ្រឹះរបស់ចលនា ហើយត្រូវអនុវត្តតាមគោលការណ៍នៃច្បាប់មនុស្សធម៌អន្តរជាតិ ។

# ៤. គោលការណ៍គ្រឹះ ៧ ប្រការ

គោលការណ៍គ្រឹះបានប្រកាសជាផ្លូវការនៅទីក្រុងវីយែន (អូទ្រីស) ឆ្នាំ១៩៦៥ មាន៖

- ភាពមនុស្សធម៌ — Humanity
- ភាពមិនលំអៀង — Impartiality
- អព្យាក្រឹតភាព — Neutrality
- ឯករាជ្យភាព — Independence
- សេវាកម្មស្ម័គ្រចិត្ត — Voluntary Service
- ឯកភាព — Unity
- សាកលភាព — Universality

# គោលការណ៍គ្រឹះ ៧ ប្រការ

## ភាពមនុស្សធម៌



ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម កើតឡើងដោយបំណងប្រាថ្នា សំដៅជួយជនរងរបួសនៅក្នុងសមរភូមិដោយមិនបែងចែក ឬរើសអើង។ ខិតខំខ្នះខ្នែង ទៅតាមសមត្ថភាពជាតិ និងអន្តរជាតិរបស់ខ្លួន ដើម្បីបង្ការ និងកាត់បន្ថយទុក្ខលំបាកវេទនា របស់មនុស្សលោកគ្រប់ទីកន្លែងដែលជួបប្រទះ។ គោលបំណងនៃចលនាគឺការពារជីវិត និងសុខភាព ហើយធានាការគោរពមនុស្សលោក។ ចលនានឹងលើកកម្ពស់ការយោគយល់គ្នាទៅវិញ-ទៅមក មិត្តភាព សហប្រតិបត្តិការ និងសន្តិភាពស្ថិតស្ថេរ ក្នុងចំណោមជនគ្រប់រូប។

# គោលការណ៍គ្រឹះ ៧ ប្រការ

## ភាពមិនលំអៀង



ជាភាពមិនបែងចែក ឬ រើសអើងសញ្ជាតិ ពូជសាសន៍ ជំនឿសាសនា វណ្ណៈ ឬ ទស្សនៈនយោបាយឡើយ។ ភាពមិនលំអៀង ខិតខំប្រឹងប្រែង សម្រាលការឈឺចាប់ខ្លោចផ្សារបស់ជនគ្រប់រូប ដោយចំពោះតែអ្នកដែលត្រូវការចាំបាច់ឲ្យជួយ និងជូនអាទិភាពដល់ករណីដែលជាគ្រោះអាសន្នជាងគេ។

# អព្យាក្រឹតភាព



ដើម្បីបន្តរក្សាក្តីសោមនស្សរីករាយ និង ជំនឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន ចលនា មិនគប្បីចូលរួមក្នុងការវែកញែករកខុសត្រូវក្នុងបញ្ហានយោបាយ ពូជសាសន៍ ជំនឿសាសនា មនោគមន៍វិជ្ជាឡើយ។

# គោលការណ៍គ្រឹះ ៧ ប្រការ

## ឯករាជ្យភាព



ចលនាត្រូវតែឯករាជ្យ សមាគមជាតិទោះជាជំនួយការក្នុងការផ្តល់សេវាកម្មមនុស្សធម៌របស់រដ្ឋាភិបាល និងស្ថិតនៅក្រោមច្បាប់របស់ប្រទេសជាតិក៏ដោយ ក៏ជានិច្ចកាលត្រូវតែរក្សាស្វ័យភាពរបស់ខ្លួន ដើម្បីអាចធ្វើសកម្មភាពបានស្របតាមគោលការណ៍គ្រឹះនៃចលនា។

# គោលការណ៍គ្រឹះ ៧ ប្រការ

## សេវាកម្មស្ម័គ្រចិត្ត



គឺជាអង្គការសង្គ្រោះដោយស្ម័គ្រចិត្តមួយ ដែលមិនមែនធ្វើសកម្មភាព ដោយសារតែចង់បានផលចំណេញនោះឡើយ។

# គោលការណ៍គ្រឹះ ៧ ប្រការ

## ឯកភាព



នៅក្នុងប្រទេសមួយ អាចមានសមាគមជាតិតែមួយគត់ សមាគមជាតិនោះ ត្រូវតែបើកចំហ
ជូនជនគ្រប់រូប ហើយត្រូវបំពេញភារកិច្ចមនុស្សធម៌ នៅទូទាំងប្រទេស។

# គោលការណ៍គ្រឹះ ៧ ប្រការ



## សកលភាព

ចលនាអន្តរជាតិ កាកបាទក្រហម អឌ្ឍចន្ទក្រហម ក្នុងនោះគ្រប់សមាគមជាតិទាំងអស់ មានឋានៈស្មើគ្នា មានការទទួលខុសត្រូវ និងករណីកិច្ចដូចៗគ្នា ក្នុងការជួយគ្នាទៅវិញ-ទៅមក គឺជាលក្ខណៈសកល។

# ៥- បដិរូប កាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## បដិរូប

## កាកបាទក្រហម អឌ្ឍចន្ទក្រហម
## គ្រីស្តាល់ក្រហម



# បដិរូប កាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

- កាកបាទក្រហម បង្កើតនៅឆ្នាំ ១៨៦៣/១៨៦៤
- អឌ្ឍចន្ទក្រហម បង្កើតនៅឆ្នាំ ១៩២៩
- គ្រីស្តាល់ក្រហម បង្កើតនៅថ្ងៃទី៨ ធ្នូ ២០០៥

# បដិរូប កាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម



ទង់ជាតិប្រទេសស្វីស



បដិរូបកាកបាទក្រហម

បដិរូបកាកបាទក្រហម គឺ កើតឡើងពីការប្រើបញ្ច្រាស់ពីទង់ជាតិស្វីស ដែលជាកាកបាទស លើផ្ទៃពណ៌ក្រហម ទៅជាកាកបាទក្រហមលើផ្ទៃពណ៌ស

# បដិរូបភាពកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## របៀបប្រើបដិរូបភាពកាកបាទក្រហម អឌ្ឍចន្ទក្រហម

ការប្រើប្រាស់មាន២យ៉ាង៖

- បដិរូបប្រើជាឧបករណ៍ការពារ ( ទម្រង់ធំ )
- បដិរូបមានរំលេចដោយអក្សរសម្គាល់អង្គភាព ( ទម្រង់តូច )

## របៀបប្រើបដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម សម្រាប់ការពារ ( ទម្រង់ធំ )

### បដិរូបប្រើសម្រាប់ការពារ

- សម្រាប់បុគ្គលិកពេទ្យយោធា និង បុគ្គលិក សាសនាបរិក្ខារពេទ្យ កងកម្លាំងពេទ្យនៃ សមាគមជាតិ បដិរូបត្រូវប្រើតែសញ្ញា កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហមលើផ្ទៃស ហើយមានទំហំធំ។







# បដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## របៀបប្រើបដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម ជាសញ្ញាផ្តល់ដំណឹង(ទម្រង់តូច)

## គឺជាការប្រើបដិរូប មានរំលេចដោយអក្សរសម្គាល់អត្តភាព

- អាយ.ស៊ី.អរ.ស៊ី (ICRC)

ICRC

- សហព័ន្ធអន្តរជាតិ (IFRC)

- សមាគមជាតិ កាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម (NS)



# បដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## ស្ថាប័នដែលអាចប្រើបដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម បាន៖

ICRC

គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម

សហព័ន្ធអន្តរជាតិ នៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

សមាគមជាតិកាកបាទក្រហម ឬ អឌ្ឍចន្ទក្រហម

សេវាកម្មពេទ្យយោធា

# បដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

ការប្រើប្រាស់ខុស នូវបដិរូបកាកបាទក្រហម

**ការធ្វើប្រដូចជាការខុសច្បាប់**

គ្រិស្តបរិស័ទ

**ខោ ✚ អាវ = 5$**

# បដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## ការប្រើប្រាស់ខុស នូវបដិរូបកាកបាទក្រហម

**សូមប្តូរពីពណ៌ក្រហមទៅពណ៌ផ្សេង**



# វិធានការផ្តន្ទាទោសអំពើល្មើស និងឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបាន កំណត់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ






## បដិរូបភាពកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

### មណ្ឌលសុខភាព



# បដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## ក្រសួងសុខាភិបាល

# បដិរូប កាកបាទក្រហម អឌ្ឍចន្ទក្រហម គ្រីស្តាល់ក្រហម

## ព្រះរាជក្រឹត្យ ស្តីពីការប្រើប្រាស់ និង ការការពារបដិរូប កាកបាទក្រហម អឌ្ឍចន្ទក្រហម

**ព្រះរាជក្រឹត្យ នស/រកត/០៥០២/១១២**
**ស្តីពីការប្រើប្រាស់ និង ការការពារបដិរូប**
**កាកបាទក្រហម និង អឌ្ឍចន្ទក្រហម**

ឡាយព្រះហស្តលេខា ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០២

មាន ៨ ជំពូក និង ១៦មាត្រា

## ក្នុងករណីប្រើខុស៖

- សមាគមជាតិ ធ្វើរបាយការណ៍ជូនអាជ្ញាធរ
- អាជ្ញាធរ មានតួនាទីដោះស្រាយតាមបែបបទ និងតាមច្បាប់
- អាយ.ស៊ី.អរ.ស៊ី រួមជាមួយសមាគមជាតិ ធ្វើការផ្ទាល់ជាមួយអាជ្ញាធរ

# ៧- កាកបាទក្រហមកម្ពុជា

- កាកបាទក្រហមកម្ពុជា មាននិមិត្តសញ្ញា ដែលមានសញ្ញាកាកបាទពណ៌ក្រហម ស្ថិតនៅលើផ្ទៃពណ៌ស មានពាក្យជាភាសាខ្មែរថា ( កាកបាទក្រហមកម្ពុជា ) និងជាភាសាអង់គ្លេស ( Cambodian Red Cross ) ស្ថិតនៅចន្លោះខ្សែរណ្ដារង្វង់ពណ៌ខៀវ។

## ៧.១- ប្រវត្តិ

- សមាគមជាតិកាកបាទក្រហមកម្ពុជា (កក្រក) ឬ ហៅកាត់ខ្លីថា កាកបាទក្រហមកម្ពុជា គឺជាអង្គការមនុស្សធម៌ ធំជាងគេបំផុតនៅក្នុងប្រទេស។
- កាកបាទក្រហមកម្ពុជា បានបង្កើតឡើងនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៥៥ ហើយត្រូវទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា ថាជាជំនួយការឲ្យអាជ្ញាធរសាធារណៈ ដោយព្រះរាជក្រឹត្យ លេខ ៣៧៨ នស ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ១៩៥៨ និងព្រះរាជក្រឹត្យ លេខ ១១៣ នស ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០០២។

**កាកបាទក្រហមកម្ពុជា ជាសមាជិកទី៨៥ របស់សហព័ន្ធអន្តរជាតិ**

# ថ្នាក់ដឹកនាំកំពូល កាកបាទក្រហមកម្ពុជា

- ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** ជាព្រះប្រធានគណៈកម្មាធិការបង្រួបបង្រួម កាកបាទក្រហមកម្ពុជា ពីឆ្នាំ១៩៩២ ដល់ឆ្នាំ ១៩៩៤។
- សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាព្រះប្រធានកាកបាទក្រហមកម្ពុជា ពីឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៧០ និងជាព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា ពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន។

# ថ្នាក់ដឹកនាំកំពូល កាកបាទក្រហមកម្ពុជា

- **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន យោងតាម៖

| | |
|---|---|
| ✓ មហាសន្និបាត អាណត្តិទី១ | ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៤ |
| ✓ មហាសន្និបាត អាណត្តិទី២ | ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៨ |
| ✓ មហាសន្និបាត អាណត្តិទី៣ | ថ្ងៃទី៥ ខែសីហា ឆ្នាំ២០០២ |
| ✓ មហាសន្និបាត អាណត្តិទី៤ | ថ្ងៃទី៤-៥ ខែសីហា ឆ្នាំ២០០៦ |
| ✓ មហាសន្និបាត អាណត្តិទី៥ | ថ្ងៃទី៤-៥ ខែសីហា ឆ្នាំ២០១០ |
| ✓ មហាសន្និបាត អាណត្តិទី៦ | ថ្ងៃទី៦-៧ ខែសីហា ឆ្នាំ២០១៤ |

# ស្ថិតិធនធានមនុស្ស របស់កាកបាទក្រហមកម្ពុជា

## ធនធានមនុស្សរបស់ កាកបាទក្រហមកម្ពុជា

| | | |
|---|---|---|
| ❖ គណៈកម្មាធិការកណ្តាល | ២៦ | នាក់ |
| ❖ សមាជិកបម្រុង | ២ | នាក់ |
| ❖ ឥស្សរជន | ៣ | នាក់ |
| ❖ មន្ត្រី-បុគ្គលិកទីស្នាក់ការកណ្តាល | ១១៤ | នាក់ |
| ❖ កាកបាទក្រហមកម្ពុជា មានសាខាចំនួន | ២៥ រាជធានី-ខេត្ត | |
| ❖ គណៈកិត្តិយសសាខា | ៤២៨ | នាក់ |
| ❖ គណៈកម្មាធិការសាខា រាជធានី-ខេត្ត | ៣១៤ | នាក់ |
| ❖ សមាជិកបម្រុងសាខា | ៤១ | នាក់ |
| ❖ មន្ត្រី-បុគ្គលិកសាខា | ២៦៤ | នាក់ |
| ❖ គណៈកិត្តិយសអនុសាខា | ១,៣៨៨ | នាក់ |
| ❖ គណៈកម្មាធិការអនុសាខា | ១,៤៥០ | នាក់ |
| ❖ អ្នកស្ម័គ្រចិត្ត (២០១៨) | ២២.៨៧៨ | នាក់ |
| ❖ យុវជន (២០១៨) | ២៤.៩០៨ | នាក់ |

# កាកបាទក្រហមកម្ពុជា

កាកបាទក្រហមកម្ពុជា បំពេញការងារដោយអនុលោមតាមឯកសារគតិយុត្តជាច្រើន មានដូចជា៖ លក្ខន្តិកៈ វិធាននីតិក្រម បទប្បញ្ញត្តិហិរញ្ញវត្ថុ ទម្រង់ការណ៍ហិរញ្ញវត្ថុ យុទ្ធសាស្រ្ត ២០១១-២០២០ គោលនយោបាយ និងគោលការណ៍ណែនាំជាច្រើនទៀត។

កាកបាទក្រហមកម្ពុជា មានទស្សនវិស័យ៖ រួមចំណែកពន្លឿនការកាត់បន្ថយភាពក្រីក្រ ការពារសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ និងការពារតម្លៃមនុស្សធម៌របស់ជនរងគ្រោះ និងបានកំណត់នូវទិសយុទ្ធសាស្រ្ត ២០១១-២០២០ ជាជំហានត្រូវអនុវត្តរួមមាន៖

# ៨- សកម្មភាព សាខាកាកបាទក្រហមកម្ពុជា

## សកម្មភាពសាខា

- ❖ សាខាកាកបាទក្រហមកម្ពុជា ខេត្ត
- ➢ បានបង្កើតឡើងនៅថ្ងៃទី .......... ខែ .......... ឆ្នាំ ...........
- ➢ ប្រធានកិត្តិយស៖ .....................................................
- ➢ អនុប្រធានកិត្តិយស៖ ..................................................
- ➢ នាយក៖ .....................................................................
- ➢ នាយករង៖ ................................................................
- ➢ មន្ត្រី៖ .......................................................................
- ➢ អាស័យដ្ឋានទីស្នាក់ការសាខា៖ ...............................
- ➢ ចេនាសម្ព័ន្ធសាខា អនុសាខា៖ ...................................
- ➢ ទូរស័ព្ទលេខ៖ .............................................................
- ➢ អ៊ីមែល៖ .....................................................................

# សកម្មភាព សាខាកាកបាទក្រហមកម្ពុជា

## សកម្មភាពសាខា (គ)

សូមរៀបរាប់ពីសកម្មភាពសាខារបស់លោកអ្នក (សកម្មភាពស្នូល និងសកម្មភាពគម្រោង)

❖ សកម្មភាពវិស័យស្នូលទី១ (ការគ្រប់គ្រងគ្រោះមហន្តរាយ)

- ..................................................................................
- ..................................................................................
- ..................................................................................

❖ សកម្មភាពវិស័យស្នូលទី២ (សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍)

- ..................................................................................
- ..................................................................................
- ..................................................................................

# សកម្មភាព សាខាកាកបាទក្រហមកម្ពុជា

## សកម្មភាពសាខា ( ត )

- សកម្មភាពវិស័យស្នូលទី៣ (លើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា)
  - ..........................................................................
  - ..........................................................................
  - ..........................................................................
- សកម្មភាពវិស័យស្នូលទី៤ (អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន)
  - ..........................................................................
  - ..........................................................................
  - ..........................................................................

# ៩- សមាជិកភាព កាកបាទក្រហមកម្ពុជា

## សមាជិកភាព

- សមាជិក គឺជាប្រភពធនធានមនុស្ស និងហិរញ្ញវត្ថុសម្រាប់សមាគមជាតិនីមួយៗ។ ពលរដ្ឋ គ្រប់រូបដែលបានចុះឈ្មោះជាសមាជិកកាកបាទក្រហមកម្ពុជា មានន័យថាបានចូលរួមចំណែក ក្នុងសកម្មភាពមនុស្សធម៌ ជួយសម្រាលទុក្ខលំបាករបស់អ្នកងាយរងគ្រោះបំផុត ដោយការបង់ ប្រាក់សមាជិកភាពប្រចាំឆ្នាំរបស់ខ្លួន។
- សមាជិកភាពរបស់កាកបាទក្រហមកម្ពុជា ត្រូវបានបើកទូលាយសម្រាប់ជនគ្រប់រូប ដោយមិន បែងចែកពូជសាសន៍ ភេទ ជំនឿសាសនា ភាសា វណ្ណៈ ឬ ទស្សនៈនយោបាយឡើយ។ បុគ្គល មិនមែនជាពលរដ្ឋកម្ពុជា ក៏អាចចូលជាសមាជិករបស់កាកបាទក្រហមកម្ពុជា បានដែរ។

# សមាជិកភាព ភាកាទក្រហមកម្ពុជា

## សមាជិកភាព ( គ )

### ប្រភេទសមាជិក និង ប្រាក់សមាជិកភាពប្រចាំឆ្នាំ

១- សមាជិកកិត្តិយស៖ ត្រូវបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំ ចំនួន ២,០០០,០០០៛ ក្នុង ១ឆ្នាំ

២- សមាជិកឧបការី៖ ត្រូវបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំ ចំនួន ៨០០,០០០៛ ក្នុង ១ឆ្នាំ

៣- សមាជិកសកម្ម៖ អ្នកដែលបានផ្តល់សេវាកម្មពិសេស សេវាកម្មស្ម័គ្រចិត្ត។

៤- សមាជិកទ្រទ្រង់ មានចំនួន ៧ ថ្នាក់គឺ៖

- ទ្រទ្រង់ថ្នាក់ទី១ ២០០,០០០៛
- ទ្រទ្រង់ថ្នាក់ទី២ ១៥០,០០០៛
- ទ្រទ្រង់ថ្នាក់ទី៣ ១០០,០០០៛
- ទ្រទ្រង់ថ្នាក់ទី៤ ៥០,០០០៛
- ទ្រទ្រង់ថ្នាក់ទី៥ ១០,០០០៛
- ទ្រទ្រង់ថ្នាក់ទី៦ ៥,០០០៛
- ទ្រទ្រង់ថ្នាក់ទី៧ ៣,០០០៛


Oddar Meanchey
Banteay Meanchey
Siem Reap
Preah Vihear
Stung Treng
Ratanakiri
Battambang
Pailin
Kampong Thom
Kratie
Mondulkiri
Pursat
Kampong Chhnang
Kampong Cham
Tbong Kmoum
Koh Kong
Kampong Speu
Phnom Penh
Kandal
Prey Veng
Svay Rieng
Takeo
Kampot
Preah Sihanouk
Kep

សូមអរគុណ

# កាកបាទក្រហមកម្ពុជា


| | |
|---|---|
| អាសយដ្ឋាន៖ | ឡូត៍១៦អា ផ្លូវលេខ ៦៥២ កែងផ្លូវ ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ទូរស័ព្ទ៖ | ០២៣ ៨៨១ ៥១១ |
| អ៊ីមែល៖ | info@redcross.org.kh / crc_adm@online.com.kh |
| ហ្វេសប៊ុក៖ | www.facebook.com/crcnhq |
| គេហទំព័រ៖ | www.redcross.ork.kh |